Public Works
LOS ANGELES COUNTY

# សមធម៌នៅក្នុងគំនិតផ្តួចផ្តើមហេដ្ឋារចនាសម្ព័ន្ធ

## ការផ្លាស់ប្តូរវិធីរបៀបដែលយើងបម្រើសេវាកម្មដល់ ខោនធី Los Angeles

សមធម៌នៅក្នុងគំនិតផ្តួចផ្តើមហេដ្ឋារចនាសម្ព័ន្ធ របស់ទីភ្នាក់ងារសាធារណការ (Public Works) ត្រូវបានបង្កើតឡើងដើម្បីកំណត់ និងដោះស្រាយលើភាពមិនស្មើគ្នាទាំងឡាយដែលកើតមានទូទាំងខោនធី នៅក្នុងការធ្វើផែនការ ការដឹកជញ្ជូន និងការចែកចាយការវិនិយោគ និងសេវាកម្មរបស់ខ្លួន។ បង្ហាញទិសដោយការពិនិត្យឡើងវិញលើគោលនយោបាយ ការវិភាគលើការវិនិយោគ និងការ ចូលរួមពីសហគមន៍ ទីភ្នាក់ងារសាធារណការកំពុងបោះជំហាននាំមុខគេដើម្បីធ្វើការដោះស្រាយលើ តម្រូវការរបស់សហគមន៍ទាំងឡាយ ដែលមានប្រវត្តិជួបការលំបាក ដើម្បីរៀបចំផែនការដឹកជញ្ជូន និងចែកចាយសេវាកម្មឱ្យបានកាន់តែប្រសើរឡើង។

ក្រុមប្រឹក្សាត្រួតពិនិត្យនៃខោនធី Los Angeles បានផ្តល់អាទិភាពដល់ការប្តេជ្ញាចិត្តក្នុងការបម្រើសេវាកម្មប្រកបដោយសមភាពជូនសហគមន៍ដែលជាកន្លែងដែលមានការលំបាកប្រមូលផ្តុំ ដើម្បីលុបបំបាត់គម្លាតការប្រើប្រាស់ពាក់ព័ន្ធនឹងពូជសាសន៍។ គោលបំណងរបស់ទីភ្នាក់ងារសាធារណការ គឺបង្កើត និងពន្លឿនរបៀបវារៈប្រឆាំងការរើសអើងជាតិសាសន៍របស់ខោនធី។ លទ្ធផលទទួលបានពីគំនិតផ្តួចផ្តើមនេះនឹងជូនជាព័ត៌មានដល់គោលនយោបាយដែលផ្តោតលើសមធម៌ដែលនឹងផ្តល់អាទិភាព និងទទួលយកសំឡេងនៃសហគមន៍របស់យើងបានប្រសើរជាងមុន និងនាំទៅរកលទ្ធផលវិជ្ជមានសម្រាប់អ្នករស់នៅក្នុងខោនធីទាំងអស់ និងមនុស្សជំនាន់ក្រោយផងដែរ។



### គំនិតផ្តួចផ្តើមដែលមានច្រើនដំណាក់កាល ប្រើប្រាស់វិធីសាស្ត្រជាច្រើនដែលរួមមានដូចជា៖

**ការវិភាគលើការវិនិយោគ** ដើម្បីកំណត់ពីភាពមិនស្មើភាពគ្នានៅក្នុងការចែកចាយនៃការវិនិយោគគម្រោងហេដ្ឋារចនាសម្ព័ន្ធសាងសង់តែមួយដងកាលពីពេលថ្មីៗ និងដែលបានគ្រោងទុកនៅក្នុង ទីតាំងផ្តល់សេវាកម្ម PW ដែលមានស្រាប់

**ការវិភាគលើដំណើរការការងារ** ដើម្បីកំណត់ពីភាពមិនស្មើភាពគ្នានៅក្នុងគុណភាព នៃស្ថានភាពហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មដែលបានផ្តល់ជូនកាលពីពេល ថ្មីៗនៅក្នុងតំបន់ផ្តល់សេវារបស់ PW ដោយផ្តោតលើទីតាំង ដែលខ្វះខាត សេវាកម្ម

**ការវិភាគលើបញ្ហាបន្ទុក** ដើម្បីកំណត់ពីភាពមិនស្មើភាពគ្នានៅក្នុងវបាយ ផលប៉ះពាល់អវិជ្ជមាននានាលើសហគមន៍ចម្រុះ ជាតិសាសន៍នៅក្នុងតំបន់ផ្តល់សេវាកម្ម PW

**ការពិនិត្យឡើងវិញលើគោលនយោបាយ** ដើម្បីកំណត់ពីគោលនយោបាយ នីតិវិធី ឬការអនុវត្តដែលមានស្រាប់ ដែលបង្កើត និងរក្សានូវផលវិបាករារាំងជាលក្ខណៈប្រព័ន្ធដើម្បីសម្រេចនូវលទ្ធផលដែលស្មើភាពគ្នា

Public Works
LOS ANGELES COUNTY

# តារាងការពិតនៃទីភ្នាក់ងារ

**ទីភ្នាក់ងារសាធារណការ ខោនធី Los Angeles (Los Angeles County Public Works) គឺជាទីភ្នាក់ងារសាធារណការក្រុងដ៏ធំមួយ ក្នុងចំណោមទីភ្នាក់ងារជាច្រើននៅក្នុងសហរដ្ឋ អាមេរិក ដែលកំពុងតែផ្តល់នូវហេដ្ឋារចនា សម្ព័ន្ធ និងសេវាកម្មសំខាន់ៗនៅសតវត្សរ៍ទី 21 ដល់មនុស្សជាង 10 លាននាក់នៅទូទាំងទីតាំងផ្តល់សេវាកម្មក្នុងតំបន់ដែលមានផ្ទៃដី សរុបទំហំ 4.000 ម៉ាយការ៉េ។**

ទីភ្នាក់ងារនេះស្ថិតក្នុងចំណោមនាយកដ្ឋាន និងទីភ្នាក់ងារចំនួន 51 ខោនធី ដែលធ្វើការសហការគ្នានៅទូទាំងវិស័យសាធារណៈ ឯកជន និងមិនរកប្រាក់ចំណេញ ដើម្បីបង្កើនគុណភាពជីវិតសម្រាប់ប្រជាជន និងសហគមន៍ ទាំងឡាយនៃខោនធី LA ។

ជាមួយនឹងចក្ខុវិស័យដើម្បីក្លាយជាទីភ្នាក់ងារសាធារណៈដែលបានទុកចិត្តបំផុតនៅក្នុងតំបន់ ទីភ្នាក់ងារសាធារណការ ត្រូវបានកំណត់ដោយការឆ្លើយតបរបស់ខ្លួនចំពោះសាធារណជន ភាពល្អប្រសើរនៃសេវាកម្មអតិថិជន និងជំរុញឱ្យបង្កើតទំនាក់ទំនងសហគមន៍វិជ្ជមាន។ ក្រុមការងាររបស់យើងមានមោទនភាពក្នុងការប្តេជ្ញាចិត្តជាមន្ត្រីសាធារណៈដែលផ្តល់សេវាកម្មសំខាន់ៗ និងចាំបាច់សម្រាប់អ្នករស់នៅ និងអាជីវកម្មទាំងអស់នៅក្នុងខោនធី LA ។



**ទីតាំងសេវាកម្មស្នូលចំនួនប្រាំពីរ និងទីតាំងសេវាកម្មគាំទ្រ៖**

- **ធនធានទឹក**
- **ការដឹកជញ្ជូន**
- **សេវាកម្មផ្នែកបរិស្ថាន**
- **ការគ្រប់គ្រងសំណង់**
- **សេវាកម្មក្រុង**
- **កិច្ចសន្យាសាធារណៈ និងការគ្រប់គ្រងទ្រព្យ សកម្ម**
- **សេវាកម្មរដ្ឋបាល**

កញ្ចប់ថវិការប្រចាំឆ្នាំជាង 3.6 ពាន់លានដុល្លាររបស់ទីភ្នាក់ងារ ត្រូវបានផ្តល់មូលនិធិដោយប្រាក់ចំណូលដែលបានដាក់កម្រិត ដូចជាពន្ធឧស្ម័ន ការវាយតម្លៃអត្ថប្រយោជន៍ ការលក់ទឹក និងលូ ថ្លៃប្រើប្រាស់ និងចំណូលផ្សេងទៀត។ ទីភ្នាក់ងារនេះក៏គ្រប់គ្រងទឹក ការដឹកជញ្ជូន និងកាកសំណល់ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយស្ថេរភាព រួមទាំងគម្រោងដើមទុនសកម្មជាង 130 គម្រោង ដែលមានតម្លៃសាងសង់ជាង 3.3 ពាន់លានដុល្លារ។ ទីភ្នាក់ងារសាធារណការបានផ្តោតជាយុទ្ធសាស្ត្រលើការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមរយៈយុទ្ធសាស្ត្រប្រកបដោយភាពច្នៃប្រឌិត និងឱកាសក្នុងការចុះកិច្ចសន្យាដែលងាយស្រួលសម្រាប់អាជីវកម្ម ដើម្បីបម្រើដល់អាជីវកម្មខ្នាតតូចរបស់ខោនធី និងគោលបំណងជួលអ្នកធ្វើការងារក្នុងស្រុកផងដែរ។

នៅក្នុងឆ្នាំសារពើពន្ធ 2020-21 ទីភ្នាក់ងារសាធារណការបានផ្តល់កិច្ចសន្យាដែលមានតម្លៃជាង 1 ពាន់លានដុល្លារ ដែលបានជួយបង្កើតការងារចំនួន 12,394 ការងារ។ ក្រុមការងារចម្រុះរបស់ទីភ្នាក់ងារនេះមាននិយោជិតប្រមាណ 4,000 នាក់នៅក្នុងចំណាត់ថ្នាក់ការងារជិត 500 រួមទាំងឯកទេស អ្នកបច្ចេកទេស ស្មៀន និងសិប្បកម្មជំនាញផងដែរ។

1 ធនធាន៖ *https://lacounty.gov/government/departments-commissions-and-agencies/los-angeles-county-departments/*

ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់គេហទំព័រ៖ dpw.lacounty.gov